***ខ្លឹមសារបកប្រែនៃលិខិត***
***ដែលក្រសួងការបរទេសខ្មែរផ្ញើជូនស្ថានទូតវៀតណាមនៅភ្នំពេញ***
***ទាក់ទងនឹងរឿងព្រំដែនកម្ពុជា-វៀតណាម***

*លេខ ១៣៨០ កបទ-សអ/ច្បក៤*

*ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមសំដែងនូវគារវកិច្ចចំពោះស្ថានទូតសាធារណរដ្ឋសង្គមនិយមវៀតណាមនៅទីក្រុងភ្នំពេញ និងមានកិត្តិយសសូមទាញចំណាប់អារម្មណ៍ដល់ស្ថានទូត ដូចខាងក្រោម ៖*

*យោងតាមរបាយការណ៍របស់ក្រសួងមហាផ្ទៃកម្ពុជា និងគណៈកម្មការចម្រុះកិច្ចការព្រំដែនកម្ពុជា អាជ្ញាធរកម្ពុជានៅខេត្តរតនគិរី បានរកឃើញស្រះទឹកចំនួន ៥ ( ទំហំនីមួយៗ ៥ម.x ១៣ម.) ដែលជីកដោយអាជ្ញាធរវៀតណាម នៅចន្លោះបង្គោលព្រំដែនលេខ ៣០ និងលេខ ៤០ ដែលស្ថិតនៅក្នុងភូមិឡំ ឃុំប៉ក់ញ៉ែ ស្រុកអូយ៉ាដាវ ខេត្តរតនគិរី នៅក្នុងកំណាត់ព្រំដែនដែលមិនទាន់បានធ្វើការកំណត់ខណ្ឌសីមា។*

*យោងតាមផែនទីបាន ១/១០០.០០០ ស្រះទឹកទាំងនេះត្រូវបានជីកនៅក្នុងទឹកដីកម្ពុជាយ៉ាងជ្រៅ ៖*

- *ស្រះទឹកទី ១ និងទី ២ ជីកជាប់គ្នា មានចំងាយប្រមាណ ៣៨០ ម. ពីខ្សែព្រំដែន*
- *ស្រះទឹកទី ៣ ចំងាយប្រមាណ ៣៩០ ម. ពីខ្សែព្រំដែន*
- *ស្រះទឹកទី ៤ ចំងាយប្រមាណ ៥៤៥ ម. ពីខ្សែព្រំដែន និង*
- *ស្រះទឹកទី ៥ ចំងាយប្រមាណ ៤៧០ ម. ពីខ្សែព្រំដែន។*

*ដោយហេតុថា តំបន់នេះពុំទាន់បានកំណត់ខណ្ឌសីមានៅឡើយ រាជរដ្ឋាភិបាលកម្ពុជាស្នើរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមគោរពតាមខ្សែព្រំដែន នៃផែនទីបោន ខ្នាត ១/១០០.០០០ និងចំណុចទី ៨ នៃ**សេចក្តីប្រកាសព័ត៌មានរួម** ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ១៩៩៥ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានចែងថា......... “**ភាគីទាំងពីរឯកភាពរក្សាស្ថានភាពបច្ចុប្បន្នដដែល មិនឱ្យមានការផ្លាស់ប្តូរ ឬដកទីតាំងកំណត់សំគាល់ព្រំដែន និងអប់រំទប់ស្កាត់ពលរដ្ឋទាំងសងខាង មិនត្រូវធ្វើការដោះដុះ ឬតាំងទីលំនៅឆ្លងដែន និងសហការរក្សាសណ្តាប់ធ្នាប់ និងសន្តិសុខព្រំដែន រហូតដល់មានដំណោះស្រាយបញ្ហាព្រំដែននេះ**” ។*

*ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានកិត្តិយសជូនព័ត៌មានបន្ថែមដល់ស្ថានទូតថា នៅក្នុងជំនួបកាលពីថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០១៥ នៅទីក្រុងភ្នំពេញ ជាមួយ* ***ឯកឧត្តម ឡេ ហុងអាញ់*** *សមាជិកការិយាល័យនយោបាយបក្សកុម្មុយនីសវៀតណាម* ***សម្តេចតេជោ ហ៊ុន សែន*** *នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានលើកឡើងពីបញ្ហាព្រំដែន និងបានស្នើថា* ***"តំបន់ណាដែលពុំទាន់បានធ្វើការខណ្ឌសីមា មិនត្រូវធ្វើឱ្យមានការប្រែប្រួលទេ រហូតដល់បញ្ចប់ការខណ្ឌសីមាព្រំដែន"*** *។*

*រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៥*

*ស្ថានទូតសាធារណរដ្ឋសង្គមនិយមវៀតណាម*
***ភ្នំពេញ***

***KINGDOM OF CAMBODIA***

*Ministry of Foreign Affairs*
*and International Cooperation*

*No. 1380 MFA-IC/CL4*

*The Ministry of Foreign Affairs and International Cooperation presents its compliments to the Embassy of the Socialist Republic of Vietnam in Phnom Penh and has the honour to draw the latter's attention as follows:*

*According to the report of the Ministry of Interior of Cambodia and the Cambodian Joint Border Commission, the Cambodian authorities of Ratanakiri Province have discovered five ponds (size 5mx13m each) dug by Vietnamese authority between the Border Pillar No. 30 and 40 located at the Lom Village, Pak Nhay Commune, O Yadav District, Ratanakiri Province in a sector that the borderline has not been demarcated.*

*Based on the map Bonne 1/100.000, the ponds were dug deep inside the Cambodian territory:*

- *The first and the second ponds adjacent to each other, approximately 380 meters from the borderline;*
- *The third pond, approximately 390 meters from the borderline;*
- *The fourth pond, approximately 545 meters from the borderline and*
- *The fifth pond, approximately 470 meters from the borderline.*

*While this area has not yet been demarcated, the Royal Government of Cambodia demands the Government of the Socialist Republic of Vietnam to respect the borderline of the map Bonne 1/100.000 and the point 8 of the **Joint Press Communiqué** of 17 January 1995 between the Kingdom of Cambodia and the Socialist Republic of Vietnam, which stipulates that ............... **" Pending the solution for the outstanding border issues, the two sides agreed to maintain the***

*Address: Nº 3, Samdech Hun Sen Street, Sangkat Tonle Basac,*
*Khan Chamkamon, Phnom Penh, Kingdom of Cambodia*

*Tel : (855) 23 214 441, 216 122*
*Fax : (855) 23 216 144, 216 141*
*Email : mfaic@mfa.gov.kh*

*present management; no changing or moving of border markers; and to educate and prevent their people from carrying out cross border cultivation or settlement and to cooperate in maintaining border security and order".*

*The Ministry has further the honor to inform the Embassy that during the meeting with H.E. Mr.* ***Le Hong Anh,*** *member of Politburo of the Communist Party of Vietnam, held on 09 June 2015 in Phnom Penh,* ***Samdech Techo Hun Sen,*** *Prime Minister of the Kingdom of Cambodia, has also broached this issue and demanded that* ***" pending the demarcation of the border, the areas which have not been demarcated should not be changed".***

*The Ministry of Foreign Affairs and International Cooperation avails itself of this opportunity to renew to the Embassy the assurances of its highest considerations.*

*Phnom Penh, 12 June 2015*

*Embassy of the Socialist*
*Republic of Viet Nam*
*Phnom Penh*